**LONG BEACH UNIFIED SCHOOL DISTRICT**
**សហសាលារៀនតំបន់ឡុងប៊ីច**

SERVING LONG BEACH, LAKEWOOD, SIGNAL HILL AND AVALON

BOARD OF EDUCATION
ក្រុមប្រឹក្សាភិបាលនៃការអប់រំ
1515 HUGHES WAY
LONG BEACH, CALIFORNIA 90810-1839
(562) 997-8240 • FAX (562) 997-8280

ថ្ងៃទី១៦ កុម្ភៈ ២០១៧

មាតាបិតា សិស្សានុសិស្ស និងបុគ្គលិកជាទីមេត្រី

ប៉ុន្មានថ្ងៃមុនពេលសម្រាកបុណ្យ Thanksgiving, លោកអគ្គនាយក Chris Steinhauser បានផ្ញើសំបុត្រមួយដល់លោកអ្នកទាំងអស់គ្នាស្តីអំពីសេចក្តីបារម្ភណ៍ដែលសិស្សបានបញ្ចេញឲ្យដឹងអំពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។ សិស្សជាច្រើនមានសេចក្តីបារម្ភណ៏ទៅលើស្ថានភាពរបស់ពួកគេឬរបស់ឪពុកម្តាយពួកគេ ថាវាអាចប៉ះពាល់ដល់ពួកគេ គ្រួសារ និងមិត្តភក្តិរបស់ពួកគេនៅសាលាដោយរបៀបណា។ ក្នុងសប្តាហ៍នេះ ក្រុមប្រឹក្សាភិបាលនៃការអប់រំយើងបានបង្កើតសេចក្តីសម្រេចមួយពង្រឹងជាផ្លូវការដល់សារធានាអះអាងរបស់លោកអគ្គនាយក។ សាលារៀនរបស់យើងមិនចូលរួមក្នុងសកម្មភាពសក្តានុពលបង្ខិតបង្ខំរបស់សហព័ន្ធ ដែលសំអាងទៅលើស្ថានភាពអន្តោប្រវេសន៍ ជំនឿសាសនា ឬដើមកំណើតពូជសាសន៍ឡើយ។ យើងនឹងធ្វើគ្រប់សព្វបែបយ៉ាងដែលស្របទៅតាមច្បាប់ដើម្បីការពារសិស្សានុសិស្ស ដោយឥតគិតអំពីស្ថានភាពរបស់ពួកគេឡើយ។ តួរនាទីរបស់យើងជាអ្នកអប់រំសាធារណះ គឺដើម្បីសាគមន៍ហើយបំរើសិស្សទាំងអស់ដែលមកដល់មាត់ទ្វារនៃសាលារៀន ដោយឥតគិតអំពីស្ថានភាពនៅក្នុងជីវិតរបស់ពួកគេឡើយ។ យើងទទួលអោបក្រសោបភាពចម្រុះផ្សេងៗគ្នាថាជាថាមពលនៅសាលារៀនរបស់យើងនិងនៅក្នុងសង្គមរបស់យើង ហើយយើងនិងធ្វើឲ្យអស់ពីសមត្ថភាពរបស់យើងដើម្បីតម្រូវទៅតាមសេចក្តីត្រូវការរបស់សិស្សយើងម្នាក់ៗ។ ក្រុមអ្នកផ្តល់ឱវាទរបស់យើងព្រមទាំងបុគ្គលិកដ៏ទៃទៀតនិងជួយសិស្សណាដែលមានសេចក្តីបារម្ភណ៍អំពីស្ថានភាពអនាគតរបស់ពួកគេ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលទើបតែបានបង្កើតមកថ្មីៗនេះមានដាក់ភ្ជាប់មកជាមួយសំបុត្រនេះ។ តាងនាមជាក្រុមប្រឹក្សាភិបាលអប់រំរបស់អ្នក យើងនឹងបន្តទទួលស្វាគមន៍និងការពារសិស្សទាំងអស់ យើងនឹងធ្វើអ្វីគ្រប់សព្វបែបយ៉ាងនៅក្នុងសមត្ថភាពរបស់យើងដើម្បីការពារការបំពានដោយអយុត្តិធម៌ឬការរំខានដែលអាចជ្រៀតជ្រែកដល់គុណភាពនៃការអប់រំដែលយើងផ្តល់ឲ្យសិស្សនៅសាលារៀនយើងជារៀងរាល់ថ្ងៃ។

ដោយសេចក្តីស្មោះចំពោះ,

| | | |
|---|---|---|
| ប្រធានក្រុមប្រឹក្សាភិបាល | អនុប្រធានក្រុមប្រឹក្សាភិបាល | សមាជិកក្រុមប្រឹក្សាភិបាល |

| | |
|---|---|
| សមាជិកក្រុមប្រឹក្សាភិបាល | សមាជិកក្រុមប្រឹក្សាភិបាល |

long beach unified school district

# សេចក្តីសម្រេចលេខ 021517-A

## សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃការអប់រំរបស់សហសាលារៀនតំបន់ឡុងប៊ីច បញ្ជាក់ពីការការពារដល់សិស្សានុសិស្ស ដោយឥតគិតអំពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ

**ដោយហេតុថា** វាគឺជាសិទ្ធិរបស់កុមារគ្រប់រូប ដោយឥតគិតអំពីការកាន់សាសនា សញ្ជាតិ ពូជសាសន៍ ឬស្ថានភាពអន្តោប្រវេសន៍ ដើម្បីបានទទួលការអប់រំសាធារណៈពីថ្នាក់មត្តេយ្យដល់ទី១២ដោយទទេ ហើយនិង

**ដោយហេតុថា** សហសាលារៀនតំបន់ឡុងប៊ីចស្វាគមន៍និងគាំទ្រសិស្សទាំងអស់ ហើយនិង

**ដោយហេតុថា** ក្រសួងអប់រំមានទំនួលខុសត្រូវក្នុងការបញ្ជាក់ថាសិស្សទាំងអស់ ដោយឥតគិតអំពីការកាន់សាសនា សញ្ជាតិ ពូជសាសន៍ឬស្ថានភាពអន្តោប្រវេសន៍ ឲ្យអាចទទួលបានដោយសុវត្ថិភាពនូវការអប់រំសាធារណៈពីថ្នាក់មត្តេយ្យដល់ទី១២ ដោយទទេ ហើយនិង

**ដោយហេតុថា** សកម្មភាពរបស់អាជ្ញាធរអន្តោប្រវេសន៍សហព័ន្ធនៅលើឬនៅជិតបរិវេណរបស់ក្រសួងអប់រំនិងតាមដងផ្លូវធ្វើដំណើរទៅមកសាលារៀន ទោះបីជាសកម្មភាពនោះជាការតាមឃ្លាំមើល ការសម្ភាសន៍ ការសួរទាមទាររកព័ត៌មានផ្ទាល់ខ្លួន ការចាប់ខ្លួន ការឃុំឃាំង ឬសកម្មភាពអ្វីផ្សេងទៀតដែលធ្វើឲ្យរំខានខូចខាតដល់បរិយាកាសសិក្សារបស់សិស្សទាំងអស់ រួមទាំងសិស្សដែលមានសញ្ជាតិអាមេរិកាំង សិស្សដែលនៅលើទឹកដីសហរដ្ឋដោយស្របតាមច្បាប់ និងសិស្សដែលពុំមានសញ្ជាតិអាមេរិកាំង ហើយនិង

**ដោយហេតុថា** តាមរយៈបទបញ្ជានិងការអនុវត្តន៍របស់ខ្លួន ក្រសួងអប់រំបានប្តេជ្ញាផ្តល់ការអប់រំមានគុណភាពខ្ពស់ដល់សិស្សទាំងអស់ ដែលមានរួមទាំងបរិយាកាសសិក្សាដែលមានសុវត្ថិភាពនិងនឹងធឹង ការរក្សាម៉ោងបង្ហាត់បង្រៀនមិនឲ្យបាត់បង់ និងការតម្រូវឲ្យមករៀន ហើយនិង

**ដោយហេតុថា** សិស្សនិងមាតាបិតាបានបញ្ចេញឲ្យក្រសួងអប់រំដឹង អំពីការភ័យខ្លាចនិងការភាន់ភាំង ទៅលើសុវត្ថិភាពរាងកាយនិងផ្លូវចិត្តនៃសិស្សទាំងអស់ហើយនិងគ្រួសាររបស់គេ និងអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបាននូវការសិក្សាពីថ្នាក់មត្តេយ្យដល់ទី១២ដោយទទេ តាមរយៈសាលារៀននិងកម្មវិធីសិក្សារបស់ក្រសួងអប់រំ ហើយនិង

**ដោយហេតុថា** បុគ្គលិកនៃការអប់រំតាមធម្មតាប្រភពនៃការគាំទ្រ ធនធាននិងព័ត៌មានសម្រាប់ជួយនិងគាំទ្រសិស្សនៅក្នុងការសិក្សារបស់ពួកគេ រួមទាំងសុខភាពផ្លូវចិត្តផងដែរ។

**ដូច្នេះ សេចក្តីសម្រេចនេះគឺ** ក្រុមប្រឹក្សាភិបាលអប់រំបានអះអាងថាក្រសួងអប់រំឡុងប៊ីចគឺជាទីកន្លែងសុវត្ថិភាពសម្រាប់សិស្សទាំងអស់ គឺមានន័យថា ក្រសួងអប់រំឡុងប៊ីចគឺជាទីកន្លែងសម្រាប់សិស្សនិងមាតាបិតារបស់ពួកគេរៀនសូត្រ លូតលាស់និងស្វែងរកជំនួយ ព័ត៌មាននិងការគាំទ្រដែលទាក់ទិនទៅនឹងសកម្មភាពអាជ្ញាធរអន្តោប្រវេសន៍ដែលជ្រៀតជ្រែកនៅក្នុងការសិក្សារបស់ពួកគេ

**សេចក្តីសម្រេចគឺបន្តថែមទៀតថា** ក្រសួងអប់រំនឹងបន្តមិនអនុញ្ញាតឲ្យបុគ្គលឬអង្គការណាមួយចូលមកបរិវេណសាលារៀន បើសិនជាបរិយាកាសសិក្សាត្រូវបានរំខានដោយការចូលមកនោះ ការដែលអាចមានការរំខានជាខ្លាំងដោយសារតែវត្តមានរបស់ភ្នាក់ងារត្រួតត្រាអន្តោប្រវេសន៍និងគយសហរដ្ឋ U.S. Immigrations and Customs Enforcement Office (ICE) ឬអង្គការអាជ្ញាធរក្នុងតំបន់ឬរដ្ឋដែលប្រតិបត្តិការងារតំណាងឲ្យ ICE, សំណើរចូលមកលើបរិវេណសាលាអ្វីមួយពីអង្គការទាំងនេះត្រូវតែដាក់ប្រគល់ជូនការិយាល័យអគ្គនាយកសាលាឲ្យពិនិត្យមើលជាមុនសិន ថាតើការចូលមកនេះមានការអនុញ្ញាតដោយច្បាប់ដែរឬទេ ដោយការបញ្ជារបស់តុលាការ ឬដោយការអនុញ្ញាតផ្សេងទៀតដែលស្របទៅតាមច្បាប់ ហើយការពិនិត្យមើលនេះនឹងធ្វើឡើងជាបន្ទាន់ ប៉ុន្តែមុនភ្នាក់ងារអាជ្ញាធរអន្តោប្រវេសន៍ ឬភ្នាក់ងារណាមួយដែលប្រតិបត្តិការងារតំណាងឲ្យភ្នាក់ងារអន្តោប្រវេសន៍

អាចចូលមកលើបរិវេណសាលារៀន

**សេចក្តីសម្រេចគឺបន្តថែមទៀតថា**, នៅក្នុងការប្តេជ្ញារបស់ក្រសួងអប់រំដើម្បីការពារឯកជនភាពរបស់សិស្ស ក្រសួងអប់រំគប្បីបន្តបញ្ជាក់ថាមិនប្រមូលទិន្នន័យដែលទាក់ទងនឹងស្ថានភាពអន្តោប្រវេសន៍របស់សិស្ស ព្រោះទិន្នន័យ នេះពុំមានទាក់ទងនឹងការអប់រំ ហើយការប្រមូលទិន្ន័យអាចជាការរើសប្រកាន់ ហើយនិង

**សេចក្តីសម្រេចគឺបន្តថែមទៀតថា**, សំណើរអ្វីមួយស្តីអំពីព័ត៌មានសិស្ស ដែលមានរួមទាំងទិន្នន័យ ដែលទាក់ទងទៅនឹងសេវាកម្មដែលទទួលថវិកាពីសហព័ន្ធ ដូចជាការផ្តល់អាហារនៅសាលាដោយចុះថ្លៃឬដោយឥតគិតថ្លៃ ដែលចង់បានដោយ ភ្នាក់ងារ ICE ឬអាជ្ញាធរអន្តោប្រវេសន៍ ត្រូវតែបញ្ជូនទៅការិយាល័យអគ្គនាយកសាលាដើម្បីពិនិត្យបញ្ជាក់មើលថាស្របតាមច្បាប់សិទ្ធិនៃការអប់រំនិងឯកជភាពរបស់គ្រួសារ Family Educational Rights and Privacy Act (FERPA), ច្បាប់រដ្ឋធម្មនុញ្ញឯកជនភាពរបស់សិស្ស ស្តង់ដាសម្រាប់ដីកាតុលាកា ហើយនិងការកំណត់ផ្សេងទៀតស្តីពីការប្រាប់ឲ្យដឹង ហើយការពិនិត្យមើលនេះនឹងធ្វើឡើងជាបន្ទាន់ ប៉ុន្តែមុននឹងបញ្ចេញនូវព័ត៌មានអ្វីមួយ ហើយនិង

**សេចក្តីសម្រេចគឺបន្តថែមទៀតថា**, អង្គការដែលផ្តល់សេវាកម្មក្រោយម៉ោងសាលា ឬក្រុមហ៊ុនផ្តល់សេវាកម្មផ្សេងៗទៀត ដែលមានជាប់កិច្ចសន្យាពាណិជ្ជកម្មជាមួយក្រសួងអប់រំ គប្បីត្រូវបានចែកចាយនូវសេចក្តីសម្រេចនេះ ក្នុងអំឡុងរយៈពេល៣០ថ្ងៃ ហើយត្រូវបានតម្រូវឲ្យគោរពតាមសេចក្តីសម្រេចនេះ ហើយនិង

**សេចក្តីសម្រេចគឺបន្តថែមទៀតថា**, ក្រសួងអប់រំគប្បីចែកចាយសេចក្តីសម្រេចនេះទៅឲ្យបុគ្គលិកសាលា សិស្ស និងមាតាបិតា ដោយប្រើវិធីចែកចាយព័ត៌មានឬធ្វើទំនាក់ទំនងតាមធម្មតា ហើយនិង

**សេចក្តីសម្រេចគឺបន្តថែមទៀតថា**, ក្រុមប្រឹក្សាភិបាលអះអាងបញ្ជាក់ថាបុគ្គលិកអប់រំឬគ្រូបង្រៀនរបស់ក្រសួងអប់រំ មានសេរីភាពក្នុងការអប់រំ ឲ្យពិភាក្សាសេចក្តីសម្រេចនេះនៅក្នុងម៉ោងរៀន ឲ្យតែវាសមរម្យទៅតាមអាយុ ហើយសិស្សត្រូវបានប្រាប់ឲ្យដឹងថាមានអ្នកផ្តល់ឱវាទរបស់ក្រសួងអប់រំសម្រាប់ពិភាក្សាអំពីប្រធានបទផ្សេងៗដែលមាននៅក្នុងសេចក្តីសម្រេចនេះ។

**បានបង្កើត ចុះហត្ថលេខា និងយល់ព្រម** នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧

ក្រុមប្រឹក្សាភិបាលនៃការអប់រំ
របស់សហសាលារៀនតំបន់ឡុងប៊ីច
ក្នុងខោនធី(ស្រុក)ឡូសអ៊ិនជើលេស រដ្ឋកាលីហ្វ័រនីញ៉ា

ដោយ: ______________________
ប្រធាន President

ដោយ: ______________________
អនុប្រធាន Vice-President

ដោយ: ______________________
សមាជិក Member

ដោយ: ______________________
សមាជិក Member

ដោយ: ______________________
សមាជិក Member